មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

# សេចក្តីប្រកាសព័ត៌មាន

## មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") ប្រារព្ធទិវានារីអន្តរជាតិ

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៦

ទិវាអន្តរជាតិនារី ត្រូវបានប្រារព្ធឡើងជារៀងរាល់ឆ្នាំ នៅថ្ងៃទី០៨ ខែមីនា នៅទូទាំងពិភពលោក ដែលជាការអបអរសាទរចំពោះសមិទ្ធផលនៃការចូលរួមចំណែករបស់ស្ត្រីនៅក្នុងសកម្មភាពសង្គម សេដ្ឋកិច្ច វប្បធម៌ និងនយោបាយ។ មូលបទសម្រាប់ទិវាអន្តរជាតិនារីនៅឆ្នាំ២០២៦ នេះគឺ «**សិទ្ធិ យុត្តិធម៌ សកម្មភាពដើម្បីស្ត្រី និងក្មេងស្រី**»។ មូលបទឆ្នាំនេះគឺការតស៊ូមតិដើម្បីឱ្យមានសិទ្ធិស្មើគ្នា ការការពារ និងសុវត្ថិភាពសម្រាប់ទាំងអស់គ្នា។

ទិវានារីអន្តរជាតិគឺជាទិវាដ៏សំខាន់ប្រចាំឆ្នាំដើម្បីឆ្លុះបញ្ចាំងអំពីបញ្ហាប្រឈមដែលបន្តកើតមាន និងភាពជោគជ័យទៅលើសមភាពយេនឌ័រ ការពង្រឹងសិទ្ធិអំណាចស្ត្រី និងការលើកកម្ពស់សិទ្ធិស្ត្រី និងក្មេងស្រី។ ទិវានេះជាឱកាសមួយដែលរំលឹកផងដែរថា ប្រទេសកម្ពុជានៅតែបន្តប្រឈមក្នុងការសម្រេចបាននូវសមភាពយេនឌ័រ និងការយល់ដឹងឱ្យបានពេញលេញអំពីសិទ្ធិស្ត្រី ខណៈដែលប្រទេសកម្ពុជាជាសង្គមបិតាធិបតេយ្យចាក់គ្រឹះយ៉ាងជ្រៅនៅក្នុងផ្នត់គំនិតយេនឌ័រ និងបទដ្ឋានសង្គម។ ឧទាហរណ៍ ឥរិយាបទនៃការបំបិទសំឡេងជនរងគ្រោះ និងជំរុញឱ្យមានវប្បធម៌ស្តីបន្ទោសលើជនរងគ្រោះជាដើម។ អំពើហិង្សាទាក់ទងនឹងយេនឌ័រនៅតែបន្តកើតមាន ហើយតួនាទីស្ត្រីនៅក្នុងការធ្វើសេចក្តីសម្រេចចិត្តនៅមានកម្រិតនៅឡើយនៅកម្ពុជា ដែលនេះរឹតតែធ្វើឱ្យមានបញ្ហាប្រឈមផងដែរ។

ក្នុងឱកាសនៃទិវានារីអន្តរជាតិឆ្នាំ២០២៦ និងមូលបទសម្រាប់ឆ្នាំនេះ ម.ស.ម.ក នឹងផ្តោតលើរឿងរ៉ាវពាក់ព័ន្ធនឹងអ្នកការពារសិទ្ធិមនុស្សជាស្ត្រីដែលត្រូវបានជាប់ពន្ធនាគារ និងកំពុងបន្តជាប់ពន្ធនាគារ ដោយសារតែសកម្មភាពតស៊ូមតិរបស់ពួកគាត់ក្នុងកិច្ចការពារសិទ្ធិមនុស្ស។ ម.ស.ម.ក នឹងលើកឡើងផងដែរនូវបញ្ហាប្រឈមដែលអ្នកការពារសិទ្ធិមនុស្សជាស្ត្រីបានជួបប្រទះ និងផលប៉ះពាល់ដោយសារកិច្ចខិតខំប្រឹងប្រែង តស៊ូមតិដើម្បីលើកកម្ពស់សិទ្ធិមនុស្ស និងលើកទឹកចិត្តដល់អ្នកផ្សេងទៀតឱ្យបន្តការតស៊ូមតិដ៏មានសារៈសំខាន់នេះ។ សកម្មភាពខាងក្រោមនេះ ម.ស.ម.ក មានគោលបំណងបង្កើនសំឡេងអ្នកការពារសិទ្ធិមនុស្សជាស្ត្រីដែលកំពុងជាប់ឃុំ និងសកម្មភាពរបស់ពួកគាត់ ព្រមទាំងដើម្បីផ្តល់ជាកាលើកទឹកិចត្តដល់អ្នកការពារសិទ្ធិមនុស្សជាស្ត្រីជំនាន់ក្រោយ និងអ្នកដឹកនាំនាពេលអនាគត។

ក្នុងការប្រារព្ធទិវានារីអន្តរជាតិប្រចាំឆ្នាំនាខែមីនា ឆ្នាំ២០២៦ ម.ស.ម.ក នឹងរៀបចំសកម្មភាពជាបន្តបន្ទាប់ដូចខាងក្រោម៖

- ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២៦៖ ការបើកឱ្យមានការចុះឈ្មោះពីសាធារណៈជនដើម្បីចូលរួមកម្មវិធីទិវានារីអន្តរជាតិផ្ទាល់នៅថ្ងៃ៥ ខែមីនា ឆ្នាំ២០២៦
- ថ្ងៃទី៥ ខែមីនា ឆ្នាំ២០២៦៖ ការចេញផ្សាយពីសកម្មភាពរបស់អ្នកការពារសិទ្ធិមនុស្សជាស្ត្រី
- ថ្ងៃទី៥ ខែមីនា ឆ្នាំ២០២៦៖ ការប្រារព្ធទិវានារីអន្តរជាតិ
- ថ្ងៃទី៦ ខែមីនា ឆ្នាំ២០២៦៖ កម្មវិធីវិទ្យុ "ការផ្តល់អំណាចដល់ស្ត្រី"
- ថ្ងៃទី៦ ខែមីនា ឆ្នាំ២០២៦៖ ការចេញផ្សាយពីប្រវត្តិសកម្មភាពរបស់អ្នកការពារសិទ្ធិមនុស្សជាស្ត្រី
- ថ្ងៃទី៧ ខែមីនា ឆ្នាំ២០២៦៖ ការចេញផ្សាយពីប្រវត្តិសកម្មភាពរបស់អ្នកការពារសិទ្ធិមនុស្សជាស្ត្រី
- ថ្ងៃទី៩ ខែមីនា ឆ្នាំ២០២៦៖ ការផ្សាយវីដេអូ (កុំភ្លេចពួកយើង! បន្តដំណើរទៅមុខ)
- ថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៦៖ កម្មវិធីវិទ្យុ "តួនាទីស្ត្រីក្នុងការកសាងសន្តិសុខ និងសុវត្ថិភាព"
- ថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៦៖ កម្មវិធីវិទ្យុ "ភាពសកម្មរបស់ស្ត្រីក្នុងបណ្តាញសង្គម"
- ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៦៖ កម្មវិធីវិទ្យុ "សំឡេងស្ត្រី និងការជួបប្រជុំដើម្បីសិទ្ធិការងារ"

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង លោក លឹម បូរិន អ្នកសម្របសម្រួលគម្រោងនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ តាមរយៈទូរស័ព្ទ + ៨៥៥ (០) ១២ ៩០៤ ២៦៦ ឬ អ៊ីម៉ែល: borin.lim@cchrcambodia.org ៕

– ចប់ –

**បណ្ណាធិការ៖**

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា («ម.ស.ម.ក») បង្កើតឡើងក្នុងឆ្នាំ២០០២ ជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ មិនចូលបក្សសម្ព័ន្ធដែលធ្វើការដើម្បីលើកកម្ពស់ និងការពារសិទ្ធិមនុស្ស ជាពិសេសសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅព្រះរាជាណាចក្រកម្ពុជា។

ម.ស.ម.ក ជាសមាជិកនៃដៃគូសន្ធនាអន្តរជាតិដើម្បីសេរីភាពបញ្ចេញមតិ (IFEX) បណ្តាញសកលដើម្បីសេរីភាពខាងការបញ្ចេញមតិ និងសម្ព័ន្ធពិភពលោកដើម្បីការចូលរួមពលរដ្ឋ (CIVICUS) ។ ម.ស.ម.ក ក៏ជាសមាជិកនៃអង្គការពិភពលោកប្រឆាំងនឹងទារុណកម្ម (OMCT) ជាសមាជិក OECD-Watch ជាសមាជិកនៃបណ្តាញប្រឆាំងទារុណកម្ម អែស អូ អែស និងសម្ព័ន្ធសារព័ត៌មានអាស៊ីអាគ្នេយ៍ (SEAPA) ផងដែរ។

គេហទំព័រអំពីសិទ្ធិមនុស្សកម្ពុជា www.sithi.org ជាជ័យលាភីដែលបានទទួលពានរង្វាន់មូលនិធិនៃការបង្កើតសារព័ត៌មានថ្មីប្រចាំឆ្នាំ២០១១ស្ថិតក្នុងប្រភេទ «សិទ្ធិ និងសេរីភាព» និងជាជ័យលាភីទទួលពានរង្វាន់ក្នុងឆ្នាំ២០១៣ ផ្នែកទំនាក់ទំនងដើម្បីផ្លាស់ប្តូរសង្គមមកពីមជ្ឈមណ្ឌលសម្រាប់ទំនាក់ទំនង និងការផ្លាស់ប្តូរសង្គមនៅសាកលវិទ្យាល័យឃ្វីនស្លែន ក្នុងទីក្រុងប្រីសបេន ប្រទេសអូស្ត្រាលី៕